**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៣៥)

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៩

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 11-Sep-2019,10:36
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# សេចក្តីជូនដំណឹងរបស់ មាស មុត អំពីចេតនាចូលរួមក្នុងសវនាការទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ

---

**ដាក់ដោយ៖**

**សហមេធាវី៖**

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន៖**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Olivier BEAUVALLET

ចៅក្រម BAIK Kang Jin

ចៅក្រមបម្រុង Steven J. BWANA

ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី

០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៣៥)

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS (បម្រុង)

**ភាគីដើមបណ្ដឹងរដ្ឋប្បវេណីរឿងក្ដី ០០៣**

**សេចក្ដីជូនដំណឹងរបស់ មាស មុត អំពីចេតនាចូលរួមក្នុង**

**សវនាការបណ្ដឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ**

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តាមរយៈនេះជូនដំណឹងដល់អង្គបុរេជំនុំជម្រះ អនុលោមតាមសារអេឡិចត្រូនិចចុះថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០១៩[1] ថា មេធាវីការពារក្តីអាចចូលរួមនៅក្នុងសវនាការទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយរវាងពីថ្ងៃទី ២៥ ដល់ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩ និង ស្នើសុំរយៈពេលចំនួនបួនម៉ោង[2] ដើម្បីពោលប្រាស្រ័យនៅចំពោះមុខសវនាការ បន្ថែមទៅលើពេលវេលាចាំបាច់សម្រាប់ឆ្លើយតបទៅនឹងសំណួរទាំងឡាយរបស់ចៅក្រមអង្គបុរេជំនុំជម្រះដែលអាចមាន។ រយៈពេលដែលស្នើសុំនេះ គឺប្រហាក់ប្រហែលនឹងអ្វីដែលភាគីនៃរឿងក្តី ០០៤/២ ទទួលបាន[3] មានភាពចាំបាច់ក្នុងការសង្ខេបជូនអង្គបុរេជំនុំជម្រះ អំពីបញ្ហាអង្គច្បាប់ និង អង្គហេតុ ដែលមាននៅក្នុងសារណាទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោក មាស មុត[4] និង សហព្រះរាជអាជ្ញាអន្តរជាតិ[5]

---

[1] សារអេឡិចត្រូនិចពីមន្ត្រីសំណុំរឿងរបស់អង្គបុរេជំនុំជម្រះ ដែលមានចំណងជើងថា “សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស. (អ.ប.ជ. ៣៥) សេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះទៅភាគីតាមរយៈសារអេឡិចត្រូនិច” ចុះថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០១៩ (សូមមើល ឯកសារភ្ជាប់ ១)។

[2] រយៈពេលពីរម៉ោងកន្លះសម្រាប់បង្ហាញទឡ្ហីករណ៍របស់មេធាវីការពារក្តី និង រយៈពេលមួយម៉ោងកន្លះសម្រាប់ឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាអន្តរជាតិ។

[3] *រឿងក្តី អោ អាន* ០០៤/២-០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦០) ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៩ ឯកសារ D359/5 ទំព័រ ២។

[4] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ៨ ខែមេសា ២០១៩ ឯកសារ D267/4។ ចម្លើយរបស់ មាស មុត តបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៩ ឯកសារ D266/5។ ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៩ ឯកសារ D267/12។

[5] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៩ ឯកសារ D266/2។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (D267) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៩ ឯកសារ D267/10។ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយរបស់ មាស មុត តបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី ៩ ខែសីហា ឆ្នាំ ២០១៩ ឯកសារ D266/6។

និង មានសារសំខាន់សម្រាប់ធានាសិទ្ធិរបស់លោក មាស មុត ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ *ប្រកបដោយប្រសិទ្ធិភាព*។[6]

សូមលោកចៅក្រមមេត្តាទទួលយកសេចក្តីជូនដំណឹងនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី **១១** ខែកញ្ញា ឆ្នាំ **២០១៩**

សហមេធាវីការពារក្តីលោក មាស មុត

| | |
|---|---|
| ________________ | ____________________ |
| អាង ឧត្តម | Michael G. KARNAVAS |

[6] រដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខណ្ឌ អ.វ.ត.ក. ដែលរួមបញ្ចូលទាំងបទដ្ឋានយុត្តិធម៌អន្តរជាតិនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ ធានាថា ជនត្រូវចោទ និង ជនជាប់ចោទទទួលបានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ *ប្រកបដោយប្រសិទ្ធិភាព*។ *សូមមើល* មាត្រា ៣១ និង ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ១៩៩៣ ដែលកែប្រែដោយក្រមចុះថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៩៩ ប្រកាសឱ្យប្រើវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និង មាត្រាផ្សេងទៀតពីជំពូក ៨ ដល់ជំពូក ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលអនុម័តដោយរដ្ឋសភាជាតិនៅថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៩៩។ មាត្រា ៣៣ ថ្មី និង ៣៥ ថ្មី (ខ) (ឃ) នៃច្បាប់ស្តីពីបង្កើត អ.វ.ត.ក.។ វិធាន ២១(១) នៃវិធានផ្ទៃក្នុង។ មាត្រា ១៤(៣)(ខ) (ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ ដែលអនុម័តនៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៧៦ ៩៩៩ U.N.T.S. ១៧១។ *សូមមើលផងដែរ រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២-០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥៨) សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យាររយៈពេលកំណត់ និង ចំនួនទំព័រ ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៨ ឯកសារ D362/4 កថាខណ្ឌ ១០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stanišić & Župljanin* សំណុំរឿងលេខ IT-08-91-A សេចក្តីសម្រេចលើញត្តិរបស់ Mićo Stanišić និង Stojan Župljanin ស្នើសុំការផ្លាស់ប្តូរពេលវេលា និង ចំនួនពាក្យកំណត់ សម្រាប់ដាក់បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៣ ទំព័រ ២ និង ៤។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sainović និង អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-87-A សេចក្តីសម្រេចលើសំណើរួមសុំពន្យារពេលដាក់សារណារបស់អ្នកឆ្លើយតប ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៩ ទំព័រ ៤។ *សូមមើលផងដែរ រឿងក្តី Marpa Zeeland B.V. & Metal Welding B.V. តទល់នឹង ប្រទេសហូឡង់* ECtHR App. No. 46300/99 ចុះថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ២០០៤ កថាខណ្ឌ ៥១។